វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកល វិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ទីស្តីការគណៈរដ្ឋមន្ត្រី
ឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ

សង្ខេបសម្រាប់
គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០៤

# ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល នៅលើការងារក្នុងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

*ដោយបណ្ឌិត ងិន ច័ន្ទរិទ្ធ[១]*

## សេចក្តីផ្តើម

វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ទំនងជះឥទ្ធិពលធ្ងន់ធ្ងរទៅលើស្ថានភាពការងារក្នុងវិស័យសំខាន់ៗ នៃសេដ្ឋកិច្ចកម្ពុជា (កាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម)។ ការកាត់បន្ថយបុគ្គលិក ប្រាក់កម្រៃធ្លាក់ចុះ និងលក្ខខណ្ឌការងារអាក្រក់ជាងមុន ជាផលប៉ះពាល់ដ៏ចម្បងៗនៃវិបត្តិ។ សហគ្រាសធុនតូច និងមធ្យម (SMEs) រួមចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយផ្តល់ការងារដល់ ៨៥% នៃកម្លាំងពលកម្មសរុប (Kang *et al.* 2009)។ ដូច្នេះ ការពិនិត្យពីផលប៉ះពាល់នៃវិបត្តិ ទៅលើការងារក្នុង SMEs ពិតជាសំខាន់ខ្លាំងណាស់។ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើអង្កេតមួយលើ ១២០ SMEs នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ដែលអនុវត្តឡើងកាលពីខែកក្កដា-សីហា ២០១១ ដើម្បីស្វែងយល់ថា តើវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បានប៉ះពាល់យ៉ាងដូចម្តេចទៅលើការងារក្នុង SMEs ផ្នែកសំណង់ និងទេសចរណ៍។ ការពិភាក្សាក្នុងអត្ថបទនេះ ផ្តោតលើការអនុវត្តកិច្ចការជំនួញ តម្លៃទ្រព្យសកម្មជាប់លាប់ និងស្ថានភាពការងារ និងជំនួយទ្រទ្រង់ដែល SMEs ទទួលបានដើម្បីទប់ទល់នឹងវិបត្តិ ហើយបានផ្តល់ជាមតិមួយចំនួនខាងគោលនយោបាយ អំពីវិធីជួយទ្រទ្រង់ដល់ SMEs ក្រោយពេលមានវិបត្តិ។

## តើ SMEs ទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចសាកលលើផ្នែកអ្វីខ្លះ?

នៅកម្ពុជា វិបត្តិសាកលនេះ បានប៉ះពាល់ដល់ SMEs ខាងសំណង់ និងទេសចរណ៍ ទាំងលើដំណើរការអាជីវកម្ម និងតម្លៃទ្រព្យសកម្មជាប់លាប់។ សហគ្រាសភាគច្រើន (៩៤,២%) បានជួបការលំបាកចាប់ពីឆ្នាំ២០០៨ មក ដោយមាន ៩០,៨% រាយការណ៍ពី "ការធ្លាក់ចុះប្រាក់ចំណូល" និង ៣០% រាយការណ៍ពី ចំណាយកើនឡើង"។ ជារួម តម្លៃជាមធ្យមនៃទ្រព្យសកម្មជាប់លាប់របស់សហគ្រាស (មានជាអាទិ៍ ដី អគារនិងសំណង់ផ្សេងទៀត បរិក្ខារនិងម៉ាស៊ីនផ្សេងៗ សម្ភារៈដឹកជញ្ជូន គ្រឿងសង្ហារឹម) បានធ្លាក់ចុះពី ៣០៤.៧២៧ដុល្លារនៅឆ្នាំ២០០៨ មកត្រឹម ២៧៧.៥២៥ដុល្លារនៅឆ្នាំ២០១១ (ទោះបីមិនធ្លាក់ចុះខ្លាំងក្តី)។ គួរកត់សំគាល់ថា តម្លៃជាមធ្យមនៃទ្រព្យសកម្មជាប់លាប់របស់ SMEs ខាងសំណង់ បានធ្លាក់ចុះខ្លាំងពី ២៣៥.៨៥៣ដុល្លារ នៅឆ្នាំ២០០៨ មកត្រឹម ១៤០.៦៣៣ដុល្លារនៅឆ្នាំ២០១១ ដែលឆ្លុះបញ្ចាំងពីការដួលរលំវិស័យអចលនទ្រព្យ ក្នុងពេលមានវិបត្តិសេដ្ឋកិច្ច។ សម្រាប់វិស័យទេសចរណ៍ តម្លៃជាមធ្យមនៃទ្រព្យសកម្មជាប់លាប់ បានកើនឡើងតិចតួចពី ៣៣៩.១៦៤ដុល្លារក្នុងឆ្នាំ២០០៨ ដល់ ៣៤៥.៩៧១ដុល្លារក្នុងឆ្នាំ២០១១។

## តើវិបត្តិហិរញ្ញវត្ថុសាកលជះឥទ្ធិពលដល់ភាពមានការងារធ្វើក្នុង SMEs យ៉ាងដូចម្តេច?

ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលទៅលើដំណើរការអាជីវកម្ម វាជាកត្តាមួយសំខាន់សម្រាប់សហគ្រាសក្នុងការកំណត់ចំនួននិយោជិតមានប្រាក់កម្រៃ និងមិនមានប្រាក់កម្រៃ កម្រិតអប់រំរបស់និយោជិតមានប្រាក់កម្រៃ និងចំនួនប្រាក់ប៉ះប៉ូវរបស់និយោជិត។ ចំនួនពលករធ្វើការក្នុងគ្រួសារដោយគ្មានប្រាក់កម្រៃនៅក្នុង SMEs ខាងទេសចរណ៍ ធ្លាក់ចុះពី ១៣៤ គ្រួសារនៅឆ្នាំ២០០៨ មកត្រឹម ១១៤គ្រួសារនៅឆ្នាំ២០១១។ ចំនួននិយោជិតមានប្រាក់កម្រៃធ្លាក់ចុះជាបន្តបន្ទាប់ និងគួរឲ្យកត់សំគាល់ ទាំងក្នុង SMEs ខាងទេសចរណ៍ និងខាងសំណង់ ពោលគឺ ក្នុងសហគ្រាសមួយវាបានធ្លាក់ចុះជាមធ្យម ១៧,៥% (បុរស ៩,៤% ស្ត្រី ៨,០%) ក្នុងឆ្នាំ២០០៨ និង ១៥,១% (បុរស ៧,៨% ស្ត្រី ៧,៣%) ក្នុងឆ្នាំ២០១១។

លំនាំជាទូទៅដែលផុសឡើងក្នុង SMEs ទាំងពីរផ្នែកនេះ គឺចំនួននិយោជិតមានប្រាក់កម្រៃដែលមានកម្រិតអប់រំខ្ពស់ បានថយចុះក្រោយពេលសេដ្ឋកិច្ចធ្លាក់ចុះ ហើយនិយោជិតស្ត្រីមានប្រាក់កម្រៃដែលមានកម្រិតអប់រំខ្ពស់ តែងមានចំនួនតិចជាងនិយោជិតបុរសមានប្រាក់កម្រៃដែលមានកម្រិតអប់រំស្មើគ្នា ទោះបីមានឬគ្មានវិបត្តិក្តី។ ផ្នែកសំណង់ ចំនួននិយោជិតមានប្រាក់កម្រៃដែលមានកម្រិតអប់រំត្រឹម "បឋមសិក្សា" ធ្លាក់ចុះពី ៦៤៨នាក់ក្នុងឆ្នាំ២០០៨ មកត្រឹម ៤៥៣នាក់ក្នុងឆ្នាំ២០១១។ និយោជិត

[១] លោកបណ្ឌិត ងិន ច័ន្ទរិទ្ធ ជានាយក និងសាស្ត្រាចារ្យ កម្មវិធីថ្នាក់ក្រោយឧត្តមសិក្សា ផ្នែកការសិក្សាពីការអភិវឌ្ឍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

មានប្រាក់កម្រៃជាបុរស មានចំនួនច្រើនជាងស្ត្រី ទាំងសម្រាប់កម្រិតអប់រំ "បឋមសិក្សា" "អនុវិទ្យាល័យ" និង "វិទ្យាល័យ" និងទាំងក្នុងឆ្នាំ២០០៨ និង ២០១១។

ក្នុងវិស័យទេសចរណ៍ ចំនួនបុគ្គលិកមានកម្រិតអប់រំត្រឹម "អនុវិទ្យាល័យ" បានថយចុះ នេះនិយោជិតជាស្ត្រីនៅឆ្នាំ២០០៨ ក៏មានចំនួនច្រើនជាងនៅឆ្នាំ២០១១ ដែរ។ បុគ្គលិកមានកម្រិតអប់រំ "វិទ្យាល័យ" នៅឆ្នាំ២០០៨ មានចំនួនច្រើនជាង ២០១១ ហើយនៅឆ្នាំ២០០៨ បុគ្គលិកស្ត្រីមានកម្រិតអប់រំ "វិទ្យាល័យ" មានចំនួនតិចជាងបុរសមានកម្រិតអប់រំស្មើគ្នា។ បុគ្គលិកបុរសដែលមានកម្រិតអប់រំ "មហាវិទ្យាល័យនិងខ្ពស់ជាងនេះ" មានចំនួនច្រើនជាងបុគ្គលិកស្ត្រីដែលមានកម្រិតអប់រំស្មើគ្នា នៅឆ្នាំ២០០៨ និង ២០១១។

ចំពោះប្រាក់ប៉ះប៉ូវរបស់និយោជិតវិញ គ្មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ទេក្នុងផ្នែកទាំងពីរនេះ។ ទោះយ៉ាងនេះក្តី ប្រាក់កម្រៃ និងប្រាក់ខែរបស់បុគ្គលិកស្ត្រីមានកម្រិតទាបជាងបុគ្គលិកបុរស នៅមុនពេល និងក្រោយពេលមានវិបត្តិសេដ្ឋកិច្ច។ ដូច្នេះ គំលាតនៃប្រាក់ប៉ះប៉ូវរវាងនិយោជិតស្ត្រី និងបុរស មានក្នុងផ្នែកទេសចរណ៍ និងសំណង់ទាំងពីរនេះ ទោះបីជាមាន ឬគ្មានវិបត្តិក្តី។ វិបត្តិក៏បានផ្តល់កំណើនបន្តិចដែរ ដល់វិភាគទានរបស់និយោជក ទៅដល់មូលនិធិសោធននិវត្តន៍/សន្តិសុខសង្គម ក្នុងវិស័យទេសចរណ៍។

## តើ SMEs ទទួលជំនួយអ្វីសម្រាប់ទប់ទល់វិបត្តិសេដ្ឋកិច្ច?

ដើម្បីដោះស្រាយការលំបាក សហគ្រាសប្រមាណ ២៨,៣% បានកាត់បន្ថយបុគ្គលិក ១៣,៣% ធ្វើការត្បិតត្បៀតចំណាយ និង ១១,៧% កាត់បន្ថយចំណាយទឹកភ្លើងទូរស័ព្ទ ប៉ុន្តែមានសហគ្រាសត្រឹម ៣,៣% ប៉ុណ្ណោះដែលបានកាត់បន្ថយម៉ោងបុគ្គលិកធ្វើការ ៦,៧% បានកាត់បន្ថយការងារបន្ថែមម៉ោងរបស់បុគ្គលិក និង ៥,០% កាត់បន្ថយប្រាក់ខែរបស់បុគ្គលិក។ ម្យ៉ាងទៀតមានសហគ្រាសតែ ៦,៧% ប៉ុណ្ណោះដែលបានទទួលកម្ចីដើម្បីដោះស្រាយការលំបាកក្នុងអាជីវកម្មរបស់ខ្លួន និងមាន ១៨,៣% មិនបានអនុវត្តដំណោះស្រាយអ្វីទេ។ លទ្ធផលរកឃើញនេះ ឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រត្បិតត្បៀតចំណាយដែល SMEs នៅតាមបណ្តាប្រទេសអាស៊ីបានចាប់អនុវត្ត (Economist Intelligence Unit 2010)។

មានតែសហគ្រាស ១១,៧% ប៉ុណ្ណោះ ដែលទទួលបានជំនួយដើម្បីពង្រឹងដំណើរការអាជីវកម្មឡើងវិញ (៥,០% ផ្នែកសំណង់ និង ៦,៧% ផ្នែកទេសចរណ៍)។ ក្នុងចំណោមសហគ្រាសទាំងអស់ដែលទទួលបានជំនួយទ្រទ្រង់ មាន ៧៨,៦% ទទួលបានពីសាច់ញាតិ និង ២១,៤% បានពីមិត្តភក្តិ ហើយក្នុងនោះ ជំនួយជាសាច់ប្រាក់ទទួលបានពីសាច់ញាតិ មាន ៨៥,៧% និងពីមិត្តភក្តិ មាន ១៤,៣%។ ប្រាក់នេះសហគ្រាសបានប្រើប្រាស់ដើម្បីទិញផលិតផល (៣៥,៧%) ចំណាយលើប្រាក់ខែ/ប្រាក់ឈ្នួលបុគ្គលិក (៦៤,៣%) សងបំណុល (២១,៤%) និងបង្កើតផលិតផលថ្មីៗ (២៨,៦%)។ ទោះយ៉ាងនេះក្តី មានសហគ្រាសតែ ១៤,៣% ប៉ុណ្ណោះដែលបានបញ្ជាក់ថា ជំនួយនេះបានជួយខ្លួនច្រើនណាស់។ លទ្ធផលរកឃើញទាំងនោះ បានបញ្ជាក់គាំទ្រថា ឧបសគ្គចម្បងដែល SMEs នៅកម្ពុជា បានជួបប្រទះ មានកង្វះសកម្មភាពជួយទ្រទ្រង់ផ្សេងៗ និងលទ្ធភាពមានកម្រិតក្នុងការទទួលបានហិរញ្ញវត្ថុ (SMEs 2005)។

ដូចគ្នាដែរ សហគ្រាសដែលស្វែងរកសេវាកម្មជួយទ្រទ្រង់អាជីវកម្ម មានចំនួនតិចទេ ហើយភាគច្រើនបានទៅទាក់ទង "ក្រុមហ៊ុនឯកទេសឯកជន"។ លទ្ធផលរកឃើញនេះ បង្ហាញពីចំណុចខ្វះខាតដ៏សំខាន់ និងជាតួយ៉ាង (លទ្ធភាពមានកម្រិតក្នុងការទទួលបានហិរញ្ញវត្ថុ និងប្រព័ន្ធជួយទ្រទ្រង់មិនគ្រប់គ្រាន់) របស់ SMEs នៅកម្ពុជា។ សហគ្រាសនានាបានកំណត់ថា ខ្លួនត្រូវបង្កើនសមត្ថភាពដំណើរការ (ការគ្រប់គ្រង និងហិរញ្ញវត្ថុ) ភាពប្រកួតប្រជែង (បញ្ហាចោទផ្នែកផលិតផល និងថ្លៃ) និងលទ្ធភាពទទួលបានព័ត៌មានទីផ្សារ ដើម្បីកែលំអដំណើរការអាជីវកម្មរបស់ខ្លួន។

## សន្និដ្ឋាន

នៅកម្ពុជា វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បានជះឥទ្ធិពលដល់ SMEs ខាងសំណង់ និងទេសចរណ៍ លើផ្នែកដំណើរការអាជីវកម្ម និងតម្លៃទ្រព្យសកម្មជាប់លាប់។ សហគ្រាសនានាបានជួបប្រទះនូវ "ការធ្លាក់ចុះចំណូល" និង "កំណើនបន្ទុកចំណាយ"។ ជាលទ្ធផល ចំនួនពលករធ្វើការក្នុងគ្រួសារដោយគ្មានប្រាក់កម្រៃនៅក្នុង SMEs ខាងទេសចរណ៍ បានធ្លាក់ចុះ ហើយចំនួននិយោជិតមានប្រាក់កម្រៃបានធ្លាក់ចុះជាបន្តបន្ទាប់ទាំងក្នុងផ្នែកទេសចរណ៍ និងសំណង់។ លំនាំជាទូទៅមួយនៃការងាររបស់បុគ្គលិកជាបុរស និងស្ត្រី នៅក្នុង SMEs ទាំងពីរផ្នែក ក្រោយពេលមានវិបត្តិសេដ្ឋកិច្ច គឺចំនួននិយោជិតមានប្រាក់កម្រៃ ដែលមានកម្រិតអប់រំខ្ពស់បានធ្លាក់ចុះ ក្នុងនេះចំនួននិយោជិតបុរសមានប្រាក់កម្រៃដែលមានកម្រិតអប់រំខ្ពស់ មានច្រើនជាង និយោជិតស្ត្រីដែលមានកម្រិតអប់រំស្មើគ្នា ទាំងនៅមុនពេល និងក្រោយពេលមានវិបត្តិ ហើយប្រាក់កម្រៃរបស់ស្ត្រីនៅតែទាបជាងប្រាក់កម្រៃរបស់បុរស។ SMEs បានអនុវត្តយុទ្ធសាស្ត្រត្បិតត្បៀតចំណាយ ដើម្បីដោះស្រាយការលំបាក។ មានសហគ្រាសតិចតួចណាស់ដែលបានទទួលជំនួយទ្រទ្រង់ដើម្បីពង្រឹងអាជីវកម្មឡើងវិញ ហើយជំនួយនេះមានចំនួនតិច និងក្រៅផ្លូវការ។ ម្យ៉ាងទៀត មានសហគ្រាសតិចណាស់ដែលបានស្វែងរកសេវាកម្មជួយទ្រទ្រង់អាជីវកម្ម។

តាមសេចក្តីដូចខាងលើ អន្តរាគមន៍ខាងគោលនយោបាយគួរផ្តោតលើ ការបង្កើនជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ SMEs ជាពិសេស ដើម្បីជួយបំពេញកង្វះខាតនានានៅក្នុងសមត្ថភាពដំណើរការអាជីវកម្ម ភាពប្រកួតប្រជែង និងព័ត៌មានទីផ្សារ ដែលតែងធ្វើឲ្យ SMEs ត្រូវចាញ់ប្រៀបគេ។